ព្រឹទ្ធសភា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែកញ្ញា ឆ្នាំ២០២១

នៅក្នុងខែកញ្ញា ឆ្នាំ២០២១នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅ៖

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១** សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា

-បានទទួលភារកិច្ចជាប្រមុខរដ្ឋស្តីទីចំនួន១លើក។

ក-សកម្មភាពចូលរួមពិធីផ្សេងៗ

-បានអញ្ជើញទទួលព្រះរាជដំណើរ **ព្រះករុណា ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ស្តេចយាងមាតុភូមិនិវត្តន៍ ពីសាធារណរដ្ឋប្រជាមានិតចិន មកកាន់ព្រះរាជាណាចក្រកម្ពុជាវិញ

-បានចាត់ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា និងថ្នាក់ដឹកនាំខុទ្ទកាល័យសម្តេចប្រធានព្រឹទ្ធសភា នាំយកទេយ្យទាន គ្រឿងឧបភោគ បរិភោគ និងបច្ច័យរបស់សម្តេច និងលោកជំទាវ ទៅវេរប្រគេនព្រះសង្ឃ២១៤អង្គ ក្នុងពិធីកាន់បិណ្ឌវេនទី១ នៅវត្តនាគវ័ន្ត ខណ្ឌទួលគោក រាជធានីភ្នំពេញ

-បានចាត់ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភារៀបចំអំណោយចំនួន៥០០ឃីត ជូនដល់សង្កាត់ទាំង៥ ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

-បានអញ្ជើញចាក់វ៉ាក់សាំងដូសជំរុញ នៅមន្ទីរពេទ្យកាល់ម៉ែត។

ខ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ

-បានចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន១០៥ច្បាប់

-បានចុះហត្ថលេខាលើសំណើសុំព្រះរាជទានសិទ្ធិចំនួន៩០ច្បាប់

-បានទទួលព្រះរាជសារប្រទានសិទ្ធិចំនួន៩០ច្បាប់



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ: (855 23) 211 441, 211 442, 211 443 ទូរសារ: (855 23) 211 446, E-mail: oum_sarith@camnet.com.kh

-បានទទួលសំណើពីរាជរដ្ឋាភិបាលចំនួន៨៨ច្បាប់

-បានទទួលសំណើពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចំនួន១ច្បាប់

-បានទទួលសំណើពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមចំនួន១ច្បាប់

-បានចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៩ច្បាប់។

**១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុំ កា អនុប្រធានទី១ ព្រឹទ្ធសភា**

-បានទទួលភារកិច្ចជាប្រធានស្ដីទីព្រឹទ្ធសភាចំនួន១លើក។

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាតាមប្រព័ន្ធអនឡាញចំនួន១លើក។

**ខ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញនាំយកគ្រឿងឧបភោគ បរិភោគ ចង្ហាន់បិណ្ឌបាត្រ និងបច្ច័យចូលរួមក្នុងពិធីកាន់បិណ្ឌវេនទី២ នៅវត្តមុន្នីប្រសិទ្ធិវង្ស ស្ថិតក្នុងសង្កាត់ព្រែកព្នៅ ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ដើម្បីឧទ្ទិសកុសលផលបុណ្យ ជូនចំពោះញាតិការទាំងប្រាំពីរសន្ដានឥស្សរជន និងយុវជនដែលបានពលីជីវិត ដើម្បីបុព្វហេតុជាតិមាតុភូមិ ជាពិសេសដល់ដួងវិញ្ញាណក្ខន្ធ**សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** និងលោកជំទាវ **ញ៉ែម សឿន ជាស៊ីម** ដែលបានទទួលមរណកាលទៅកាន់លោកខាងមុខ

-អញ្ជើញចាក់វ៉ាក់សាំងដូសជំរុញ នៅព្រឹទ្ធសភា។

**គ-ការពិនិត្យ និងផ្ដល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៣ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៦ច្បាប់។

**១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ខេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

-បានទទួលភារកិច្ចជាប្រធានស្ដីទីព្រឹទ្ធសភាចំនួន១លើក។

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-បានអញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ុំ កា** ប្រធានស្ដីទីព្រឹទ្ធសភាចំនួន២លើក តាមប្រព័ន្ធអនឡាញ

-បានអញ្ជើញដឹកនាំសម័យប្រជុំពេញអង្គ ព្រឹទ្ធសភា លើកទី៧ នីតិកាលទី៤

ចំនួន១លើក។

**ខ-សកម្មភាពចុះមូលដ្ឋាន**

-បានអញ្ជើញចូលរួមអមដំណើរឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្តីទីព្រឹទ្ធសភា ក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី២ នៅវត្តមុន្នីប្រសិទ្ធិវង្ស ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ

-បានចាត់ក្រុមការងារនាំយកទេយ្យទានទៅចូលបុណ្យក្នុងពិធីបុណ្យកាន់បិណ្ឌវេនទី១៤ នៅវត្តចំនួន០២ ស្ថិតក្នុងស្រុកត្រាំង ខេត្តតាកែវ

-អញ្ជើញចាក់វ៉ាក់សាំងដូសជំរុញ នៅព្រឹទ្ធសភា។

**គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន៥៥ច្បាប់។

## ២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន២លើក ក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ឹម កា** ប្រធានស្តីទីព្រឹទ្ធសភា និងឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** ប្រធានស្តីទីព្រឹទ្ធសភា តាមប្រព័ន្ធអនឡាញ ដើម្បីពិនិត្យសំណើរបស់រដ្ឋសភា និងគណៈកម្មការជំនាញព្រឹទ្ធសភា សុំពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន៧ ដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា១៨ថ្មីនៃច្បាប់ស្តីពី វិសោធនកម្មមាត្រា១៨ នៃច្បាប់ស្តីពី សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា

២- សេចក្តីព្រាងច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារធ្វើវិសោធនកម្មកិច្ចព្រមព្រៀងអាស៊ានបូកបីស្តីពី ការត្រៀមបម្រុងអង្ករសង្គ្រោះបន្ទាន់

៤-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មមាត្រា១២៣ មាត្រា១៣៨ មាត្រា១៦២ មាត្រា៣០០ មាត្រា៣៤៣ មាត្រា៣៥០ មាត្រា៣៦៣ និងមាត្រា៣៦៧ នៃច្បាប់ស្តីពីការងារ ដែលត្រូវប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខៈ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧

៥-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងភាពជាដៃគូ

សេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយតំបន់

៦-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន

៧-សេចក្តីព្រាងច្បាប់ស្តីពីការប្រកួតប្រជែង

៨-ពិនិត្យ និងសម្រេចលើសំណើរបស់គណបក្សប្រជាជនកម្ពុជាលេខ: ០២៨/០៨២១/លគ.គក ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១ ។

## ៣.សម័យប្រជុំពេញអង្គព្រឹទ្ធសភា

ព្រឹទ្ធសភាបានបើកកិច្ចប្រជុំពេញអង្គចំនួន១លើក ក្រោមអធិបតីភាពឯកឧត្តមកិត្តិសង្គហបណ្ឌិត **ទេព ងន** ប្រធានស្តីទីព្រឹទ្ធសភា ដែលមានរបៀបវារៈដូចខាងក្រោម៖

១-ការប្រកាសទទួលស្គាល់សមាជិកព្រឹទ្ធសភាថ្មី នីតិកាលទី៤

២-ការបោះឆ្នោតជ្រើសរើសបំពេញសមាជិកគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ ព្រឹទ្ធសភា នីតិកាលទី៤

៣-ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន៧ច្បាប់។

## ៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិកព្រឹទ្ធសភា បានបំពេញការងារតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោម៖

### ៤.១ មុខងារនីតិកម្ម

-បានអញ្ជើញប្រជុំតាមប្រព័ន្ធអនឡាញ (ZOOM) ជាមួយតំណាងរាជរដ្ឋាភិបាល ដឹកនាំដោយឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តម **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ឯកឧត្តម **ជិន ប៊ុនស៊ាន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងលោកជំទាវ **សោម គីមសួគ** អគ្គសវនករ នៃអាជ្ញាធរសវនកម្មជាតិ ដើម្បីពិនិត្យ សិក្សាលើសេចក្តីព្រាងច្បាប់ចំនួន៧ច្បាប់។

### ៤.២ មុខងារតំណាង

-បានអញ្ជើញចូលរួមប្រជុំការងារ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចវិបុលសេនា-

ភក្តី **សាយ ឈុំ** ប្រធានព្រឹទ្ធសភា តាមប្រព័ន្ធអនឡាញ

-បានអញ្ជើញចូលរួមប្រជុំតាមប្រព័ន្ធអនឡាញជាមួយក្រុមមិត្តភាពព្រឹទ្ធសភាជាមួយសភានៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដើម្បីបូកសរុបរបាយ-ការណ៍សកម្មភាពការងារ របាយការណ៍ថវិការបស់ក្រុមប្រចាំឆមាសទី១ និងលើកទិសដៅការងារប្រចាំឆមាសទី២ និងបញ្ហាផ្សេងៗ

-បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំក្រុមអ្នកច្បាប់រាជធានីភ្នំពេញ ដើម្បីពិនិត្យពិភាក្សាស្តីពី ការងារចាត់តាំង និងបណ្តុះបណ្តាលមន្ត្រីការងារច្បាប់នៅថ្នាក់រាជធានី ខណ្ឌ សង្កាត់ មន្ត្រីការិយាល័យចុះឈ្មោះបោះឆ្នោត និងការិយាល័យបោះឆ្នោត វគ្គបណ្តុះបណ្តាលសម្រាប់រយៈពេល២ឆ្នាំ និងការបែងចែកក្រុមមេធាវីរាជធានីភ្នំពេញ ចុះជួយតាមខណ្ឌ នៅសាលារាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមប្រជុំការងារជាមួយក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំត្រពាំងប្រសាទ ខេត្តឧត្តរមានជ័យ ដើម្បីឈ្វេងយល់អំពីការងារគ្រប់គ្រង ការផ្តល់សេវាសាធារណៈ ការងារភូមិ ឃុំ មានសុវត្ថិភាព ការផ្សព្វផ្សាយ និងអប់រំប្រជាពលរដ្ឋអំពីជំងឺកូវីដ-១៩ និងបន្តអនុវត្តវិធានការ ៣ការពារ ៣កុំ របស់រាជរដ្ឋាភិបាល

-បានអញ្ជើញចូលរួមប្រជុំពិនិត្យឆ្លងរបាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆមាសទី១ ឆ្នាំ២០២១ និងលើកទិសដៅបន្តរបស់សមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ និងគណៈចលនាស្ត្រី ក្រោមអធិបតីភាពលោកជំទាវកិត្តិសង្គហបណ្ឌិត **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងជាប្រធានសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍

-បានអញ្ជើញចូលរួមប្រជុំជាមួយអនុសាខាសមាគមនារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ខណ្ឌចំការមន រាជធានីភ្នំពេញ ដើម្បីស្តាប់របាយការណ៍ និងផែនការសកម្មភាពការងារបន្តរបស់នារីខណ្ឌទាំង៥សង្កាត់រួមមានៈ សង្កាត់ទន្លេបាសាក់ សង្កាត់បឹងត្របែក សង្កាត់ទួលទំពូងទី១ សង្កាត់ទួលទំពូងទី២ និងសង្កាត់ផ្សារដើមថ្កូវ

-បានអញ្ជើញចុះជួបសំណេះសំណាលការងារ និងសួរសុខទុក្ខក្រុមប្រឹក្សាសង្កាត់ក្រាំងធ្នង់ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាលក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ ដើម្បីឈ្វេងយល់អំពីស្ថានភាពទូទៅនៃជំងឺកូវីដ-១៩ ការចាក់វ៉ាក់សាំង និងចលនាការ

ជួយដោះស្រាយជីវភាពជូនប្រជាពលរដ្ឋដែលរងផលប៉ះពាល់ក្នុងភូមិសាស្ត្រសង្កាត់ក្រាំងធ្នង់ និងការធ្វើអត្តសញ្ញាណប័ណ្ណ និងចលនាបងប្អូនប្រជាពលរដ្ឋឱ្យទៅពិនិត្យឈ្មោះ និងចុះឈ្មោះបោះឆ្នោត នៅសាលាសង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ

-បានអញ្ជើញចុះមូលដ្ឋានរាជធានីភ្នំពេញ ដើម្បីជួបសំណេះសំណាល និងសួរសុខទុក្ខមេភូមិ និងក្រុមប្រឹក្សា ដើម្បីឈ្វេងយល់អំពីស្ថានភាពទូទៅនៃជំងឺកូវីដ-១៩ ក្នុងមូលដ្ឋាន ការងារចាក់វ៉ាក់សាំងឱ្យកុមារពីអាយុ៦ឆ្នាំ ដល់១២ឆ្នាំ និងស្តាប់របាយការណ៍ស្តីពី ការខិតខំរួមសហការគ្នាប្រមូលសំណាកធ្វើ Test Rapide ជូនមាតា បិតា អាណាព្យាបាលសិស្សថ្នាក់ទី៩ និងទី១២ ដើម្បីត្រៀមលក្ខណៈបើកសាលារៀនឡើងវិញ

-បានអញ្ជើញចូលរួមសិក្ខាសាលាស្តីពីការឈ្វេងយល់អំពីការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ តាមប្រព័ន្ធអនឡាញ ផ្សាយចេញពីរដ្ឋសភា

-បានអញ្ជើញចូលរួមធ្វើជាវាគ្មិនក្នុងកម្មវិធីវេទិកាពិភាក្សាតុមូលស្តីពី ការឈានឆ្ពោះទៅរកកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុបលើកទី១៣ ក្រោមប្រធានបទ កិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុបលើកទី១១ Asian-Europe Parliamentary Partnership (ASEP11) នៅស្ថានីយទូរទស្សន៍ជាតិ

-បានអញ្ជើញចូលរួមប្រជុំពិភាក្សាជាមួយក្រុមសមាជិកព្រឹទ្ធសភា ប្រចាំភូមិភាគទី៧ លើពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋចំនួន៧២គ្រួសារ នៅក្នុងខេត្តកោះកុង

-បានទទួលពាក្យបណ្តឹងចំនួន៣ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយចំនួន៦ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន៣ករណី កំពុងពិនិត្យសិក្សាចំនួន៣ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន៦ករណី ទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធចំនួន២ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង-ស្ថាប័នពាក់ព័ន្ធ ចម្លងជូនគណៈកម្មការចំនួន២ករណី

-ដោយឡែក សមាជិក សមាជិកាព្រឹទ្ធសភាបានអញ្ជើញចុះជួបសំណេះសំណាលសាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ក្រុមគ្រូពេទ្យ ព្រមទាំងនាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋ

ដែលកំពុងជួបការលំបាក ប្រជាពលរដ្ឋរងគ្រោះមហន្តរាយផ្សេងៗ ជាពិសេសប្រជាពលរដ្ឋដែលកំពុងមានជំងឺកូវីដ-១៩ព្រមទាំងបាននាំយកទេយ្យទាន និងបច្ច័យ ប្រគេនព្រះសង្ឃនៅតាមទីវត្តអារាមនានាចំនួន៦៧លើក នៅមូលដ្ឋានរាជធានីភ្នំពេញ ខេត្តតាកែវ ខេត្តកំពង់ចាម ខេត្តកំពង់ស្ពឺ ខេត្តត្បូងឃ្មុំ ខេត្តកំពង់ធំ ខេត្តស្វាយរៀង ខេត្តកែប ខេត្តបន្ទាយមានជ័យ និងខេត្តសៀមរាប។

## ៤.៣ កិច្ចសហប្រតិបត្តិការអន្តរជាតិ

-សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំនានា រួមមាន ៖ កិច្ចប្រជុំគណៈកម្មការកិច្ចការបរទេសនៃសភាកម្ពុជា-ឡាវ-វៀតណាម(CLV), កិច្ចប្រជុំភាពជាដៃគូសភាអាស៊ី-អឺរ៉ុប Asian-Europe Parliamentary Partnership លើកទី១១ (ASEP-11), កិច្ចប្រជុំ (ASEP) ដើម្បីពិភាក្សាអំពីសេណារីយ៉ូសម្រាប់ត្រៀមដឹកនាំកិច្ចប្រជុំពិភាក្សាទី២ លើប្រធានបទការលើកកម្ពស់ការស្តារសេដ្ឋកិច្ចសកលឡើងវិញក្នុងសម័យ និងក្រោយវិបត្តិកូវីដ-១៩ Promoting Global Economic Recovery in the Era of COVID-19 and Beyong,កិច្ចប្រជុំគណៈកម្មការធ្វើសេចក្តីព្រាងប្រកាស (ASEP-11), សន្និសីទលើកទី៨ គណៈកម្មការកិច្ចការបរទេសនៃសភាកម្ពុជា-ឡាវ-វៀតណាម (CLV) ក្រោមប្រធានបទស្តីពី"ការជំរុញភាពជាដៃគូសភា ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព និងការឆ្លើយតបចំពោះវិបត្តិកូវីដ-១៩ ក្នុងតំបន់ត្រីកោណអភិវឌ្ឍន៍កម្ពុជា-ឡាវ-វៀតណាម " តាមប្រព័ន្ធអនឡាញ។

ថ្ងៃពុធ ៧ កើត ខែ អស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែតុលា ឆ្នាំ២០២១

ជ.ប្រធានព្រឹទ្ធសភា

អនុប្រធានទី២

កិត្តិសង្គហបណ្ឌិត ទេព ងន

ចម្លងជូន
- ក្រសួងព្រះបរមរាជវាំង
- ក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងយុត្តិធម៌
- ក្រសួងព័ត៌មាន
- (ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)
- កាលប្បវត្តិ-ឯកសារ